-បន្ថែមចំណាយសាងសង់បន្ទាយសវត្ថិភាពសម្តេចនាយករដ្ឋមន្ត្រីទី២ចំនួន ៧១៩.៨៣០ $US ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ២៦ អនក្រ.បក**

**ស្តីពីការបង្កើត ស្រុក កំពង់សីលា**

**ចំណុះខេត្តកោះកុង**

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២នៃរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

**សំរេច**

**មាត្រា ១** : ត្រូវបានបង្កើតស្រុកកំពង់សីលា ដោយកាត់យកភូមិសាស្ត្រស្រុកស្រែអំបិល នៃខេត្តកោះកុងទៅតាមផែនទីរដ្ឋបាលភ្ជាប់ជាមួយអនុក្រឹត្យ ។

**មាត្រា ២** :ស្រុកកំពង់សីលាត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តកោះកុង ។

**មាត្រា ៣** :ស្រុកកំពង់សីលារួមមានឃុំចំនួន ០៤ គឺឃុំស្ទឹងឆាយ ឃុំចំការហ្លួង ឃុំកំពង់សីលា និង ឃុំអូរបាក់រទេះ ។

**មាត្រា ៤** :ស្រុកកំពង់សីលា មានព្រំប្រទល់រដ្ឋបាល

- ខាងជើងជាប់នឹងស្រុកស្រែអំបិល ខេត្តកោះកុង
- ខាងត្បូងជាប់នឹងខេត្តកំពត និង ក្រុងព្រះសីហនុ
- ខាងលិចជាប់នឹងស្រុកស្រែអំបិល ខេត្តកោះកុង
- ខាងកើតទល់នឹងខេត្តកំពង់ស្ពឺ និង ខេត្តកំពត

**មាត្រា ៥** :ទីតាំងសាលាស្រុកកំពង់សីលា ស្ថិតនៅឃុំកំពង់សីលា ។

**មាត្រា ៦** :បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧** :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ១០៥ អនក្រ.គគ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា